# វិធានការណ៍សន្លឹកឆ្នោត ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០

# ពន្ធផលិតកម្មប្រេងបារ៉ែលទីក្រុងឡុងប៊ីឆ (ពន្ធបារ៉ែល/ធុង)

# សំណួរនានា ដែលបានសួរជាញឹកញាប់

*ព័ត៌មានលើសន្លឹកអង្គហេតុនេះ គឺសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ដើម្បីពិពណ៌នាអំពីផលប៉ះពាល់ជាក់ស្តែងនៃវិធានការណ៍អាមេរិក (Measure US)។ សន្លឹកអង្គហេតុព័ត៌មាននេះ មិនធ្វើការតស៊ូមតិអោយបោះឆ្នោតថាបាទ/ចាស ឬទេ ចំពោះវិធានការណ៍នេះ នោះឡើយ។*

## តើសន្លឹកឆ្នោតវិធានការណ៍នេះ ស្តីអំពីអ្វី?

- ទីក្រុងដាក់ពន្ធលើអ្នកផលិតប្រេងទាំងឡាយ សម្រាប់រាល់បារ៉ែល ឬធុងប្រេងដែលផលិតនៅឡុងប៊ីឆ។ ទីក្រុងទទួលបាន ៤៨ សេន សម្រាប់រាល់ប្រេងទាំងអស់ ដែលបានផលិតនៅឡុងប៊ិច, ៣៣ សេន សម្រាប់គោលបំណងពិសេសនានា - សុវត្ថិភាពសាធារណៈ (តាមរយៈវិធានការណ៍ H ដែលបានអនុម័តនៅឆ្នាំ ២០០៧) និង ១៥ សេន សម្រាប់គោលបំណងទូទៅនានា តាមរយៈពន្ធផលិតកម្មប្រេងបារ៉ែល ឬ Oil Barrel Production Tax ដែលមានស្រាប់ (ពន្ធបារ៉ែល/ធុង ឬ Barrel Tax)។ Measure US, ប្រសិនបើត្រូវបានអនុម័តដោយអ្នកបោះឆ្នោត, នឹងបង្កើនពន្ធបារ៉ែលទូទៅ ពី ១៥ សេន ដល់ ៣0 សេន ក្នុងមួយបារ៉ែល ហើយអនុវត្ត CPI សម្រាប់ពន្ធគោលបំណងទូទៅទាំងមូល។

## តើពន្ធបារ៉ែល/ធុង (Barrel Tax) ផ្តល់ថវិកាប៉ុន្មាន?

- ពន្ធបារ៉ែល, ដែលត្រូវបានបង់ដោយអ្នកផលិតប្រេង និងម្ចាស់រ៉ែដែលមានចំណាប់អារម្មណ៍, បច្ចុប្បន្ននេះ ផ្តល់ប្រាក់ ១.៦ លានដុល្លារ ជារៀងរាល់ឆ្នាំ នៅក្នុងចំណូលមូលនិធិទូទៅ ដល់ទីក្រុង។ វិធានការណ៍សន្លឹកឆ្នោត, ប្រសិនបើត្រូវបានអនុម័ត, នឹងបង្កើនពន្ធបារ៉ែលដល់ ៣0 សេន ក្នុងមួយបារ៉ែល, ជាមួយនឹងការកែតម្រូវ CPI ប្រចាំឆ្នាំ, ដែលជាលទ្ធផលបានប៉ាន់ប្រមាណ នូវប្រាក់ចំណូលបន្ថែម ១.៦ លានដុល្លារ នៅក្នុងចំណូលមូលនិធិទូទៅ ក្នុងឆ្នាំដំបូង ដើម្បីផ្តល់មូលនិធិដល់សេវាកម្មក្រុង។ ថវិការ/មូលនិធិ ត្រូវបានរំពឹងថា នឹងធ្លាក់ចុះនៅឆ្នាំក្រោយៗទៀត ប្រហែល ៨ ទៅ ១០ ភាគរយ ក្នុងមួយឆ្នាំ ដោយសារថា ផលិតកម្មប្រេងធ្លាក់ចុះជារៀងរាល់ឆ្នាំ។

## តើ Measure US យកពន្ធជាក់លាក់ យ៉ាងដូចម្តេច?

Measure US យកពន្ធលើការផលិតប្រេង។ មានតែអ្នកដែលមានសិទ្ធិរុករករ៉ែ និង/ឬផលិតប្រេង នៅក្នុងទីក្រុងឡុងប៊ីឆ អាចត្រូវបង់ពន្ធនេះ។ ប្រជាពលរដ្ឋទីក្រុងឡុងប៊ិច ដែលមិនមែនជាម្ចាស់សិទ្ធិរ៉ែ នឹងមិនបង់ពន្ធនេះទេ។

## តើនៅពេលណា ដែល Measure US ចាប់មានប្រសិទ្ធិភាព?

Measure US, ប្រសិនបើត្រូវបានអនុម័ត, នឹងមិនចូលជាធរមាន រហូតដល់ថ្ងៃទី ១ ខែតុលា ឆ្នាំ ២០២១។ ការប្រើប្រាស់ជាក់លាក់នៃមូលនិធិ Measure US នឹងត្រូវបានអនុម័តជាផ្នែកមួយនៃដំណើរការថវិការ FY 22 (ឆ្នាំថវិការ ចាប់ផ្តើមពីថ្ងៃទី ១ ខែតុលា ឆ្នាំ២០២១) ដោយក្រុមប្រឹក្សាក្រុង។

## វិធានការណ៍សន្លឹកឆ្នោត ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០

## ពន្ធផលិតកម្មប្រេងបារ៉ែលទីក្រុងឡុងប៊ីឆ (ពន្ធបារ៉ែល/ធុង)

## សំណួរនានា ដែលបានសួរជាញឹកញាប់

**ប្រសិនបើត្រូវបានអនុម័ត, តើថវិការ Measure US ត្រូវចំណាយយ៉ាងដូចម្តេច?**

Measure US គឺជាពន្ធទូទៅ ហើយនឹងផ្តល់ថវិការសម្រាប់សេវាកម្មទីក្រុងទូទៅនានា។ ក្រុមប្រឹក្សាក្រុង, នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២០, បានអនុម័តសេចក្តីសម្រេចចិត្តមួយ ដែលបង្ហាញពីចេតនារបស់ខ្លួន ក្នុងការផ្តល់អាទិភាព ដល់ការចំណាយនៃ Measure US សម្រាប់គោលបំណងនានា ដូចខាងក្រោមនេះ:

- បំរែបំរួលអាកាសធាតុ និងបរិស្ថានៈ អាចផ្តល់ថវិការដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់; អប់រំ និងជូនដំណឹងដល់សាធារណៈជន អំពីផលប៉ះពាល់នានា នៃការប្រែប្រួលអាកាសធាតុ; អនុវត្តន៍ផែនការសកម្មភាព និងការបន្សាំជាមួយនឹងអាកាសធាតុរបស់ទីក្រុង ឬផែនការយុទ្ធសាស្រ្តបរិស្ថានផ្សេងទៀត; លើកកម្ពស់គុណភាពខ្យល់ និងទឹក; និង, កម្មវិធីអាកាសធាតុ និងបរិស្ថានផ្សេងទៀត ដែលបានកំណត់ដោយក្រុមប្រឹក្សាក្រុង តាមរយៈដំណើរការថវិការប្រចាំឆ្នាំ។

- សុខភាពសហគមន៍: អាចផ្តល់ថវិការសម្រាប់កម្មវិធី និងសេវាកម្មសុខភាព និងសុខុមាលភាពសហគមន៍; វិធីសាស្រ្តផ្អែកលើការប៉ះទង្គិចផ្លូវចិត្ត ចំពោះតម្រូវការសហគមន៍; សេវាការពារអំពើហឹង្សា; ដោះស្រាយសមធម៌សុខភាព និងភាពខុសគ្នានៃសុខភាព នៅក្នុងចំណោមប្រជាជននានាដែលមានហានិភ័យ; អនុវត្តផែនការយុទ្ធសាស្រ្តនានា ដែលផ្តោតលើសុខភាព; និងគំនិតផ្តួចផ្តើម ដែលផ្តោតលើសុខភាពផ្សេងទៀត ដូចដែលបានកំណត់ដោយក្រុមប្រឹក្សាក្រុង តាមរយៈដំណើរការថវិការប្រចាំឆ្នាំ។

- សេវាកម្ម និងកម្មវិធីកុមារ និងយុវជន។ អាចផ្តល់ថវិការ ដើម្បីបង្កើត និងពង្រីកការអប់រំកុមារតូចៗ; កម្មវិធីយុវជន និងឱកាសសមធម៌យុវជន; អនុវត្តន៍ផែនការយុទ្ធសាស្រ្តដែលផ្តោតលើយុវជន; ឱកាសបណ្តុះបណ្តាលការងារយុវជន; និង, គំនិតផ្តួចផ្តើមផ្តោតលើកុមារ និងយុវជនដទៃទៀត ដែលបានកំណត់ដោយក្រុមប្រឹក្សាក្រុង តាមរយៈដំណើរការថវិការប្រចាំឆ្នាំ។

- ដោយអនុលោមតាមវិធានការណ៍ Measure B ដែលអនុម័តដោយអ្នកបោះឆ្នោត, ១ ភាគរយ នៃពន្ធដែលប្រមូលបាន នឹងត្រូវដាក់បញ្ចូលទៅក្នុងមូលនិធិទិវាទឹកភ្លៀងពិសេស ដើម្បីជួយរក្សានូវតុល្យភាពនៃកង្វះខាតថវិការទូទៅនាពេលអនាគត។

# វិធានការណ៍សន្លឹកឆ្នោត ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០

## ពន្ធផលិតកម្មប្រេងបារ៉ែលទីក្រុងឡុងប៊ីឆ (ពន្ធបារ៉ែល/ធុង)

## សំណួរនានា ដែលបានសួរជាញឹកញាប់

### តើការដំឡើងពន្ធ នឹងមានប្រសិទ្ធិភាពដល់រយៈពេលយូរប៉ុណ្ណា?

- ការដំឡើងពន្ធបារ៉ែល នឹងចូលជាធរមានរហូតដល់ត្រូវបានលុបចោល ដោយអ្នកបោះឆ្នោតឡុងប៊ិឆ។

### តើអត្រាពន្ធកើនឡើងយ៉ាងដូចម្តេច បើប្រៀបធៀបទៅនឹងអត្រានៅតាមទីក្រុងផ្សេងៗ?

មានអត្រាពន្ធយ៉ាងទូលំទូលាយ នៅតាមបណ្តាទីក្រុងនានា ក្នុងតំបន់ទីក្រុងដែលគិតថ្លៃសំរាប់ផលិតកម្មប្រេង, ហើយសន្ទស្សន៍ផ្សេងៗ ត្រូវបានប្រើប្រាស់ក្នុងការអនុវត្តពន្ធ។ ខាងក្រោមនេះ ជាតារាងបង្ហាញអត្រាការប្រាក់សរុបផ្សេងៗគ្នា។




### តើវាត្រូវបានគេដាក់បញ្ចូល ក្នុងសន្លឹកឆ្នោតយ៉ាងដូចម្តេច?

- ក្រុមប្រឹក្សាក្រុងបានបោះឆ្នោត នៅថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០២០ ដោយសម្លេង ៨-0 ដើម្បីដាក់វិធានការណ៍លើសន្លឹកឆ្នោតខែវិច្ឆិកា។

**វិធានការណ៍សន្លឹកឆ្នោត ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០**

**ពន្ធផលិតកម្មប្រេងបារ៉ែលទីក្រុងឡុងប៊ីឆ (ពន្ធបារ៉ែល/ធុង)**

**សំណួរនានា ដែលបានសួរជាញឹកញាប់**

## តើនរណាជាអ្នកសំរេចថា តើវិធានការណ៍នេះ បានត្រូវអនុម័ត ឬអត់?

តាមច្បាប់រដ្ឋ, ពន្ធក្នុងស្រុក ដូចជា Measure US ទាមទារនូវសេចក្តីអនុម័ត ពីអ្នកបោះឆ្នោតភាគច្រើន។ ដូច្នេះ, អ្នកបោះឆ្នោតឡុងប៊ីឆ នឹងធ្វើការសំរេចចិត្តចុងក្រោយ ថាតើត្រូវអនុម័ត ឬបដិសេធនូវវិធានការណ៍នេះ។

## តើមានអ្វីកើតឡើង ប្រសិនបើ Measure US ត្រូវបានអនុម័ត?

- ប្រសិនបើត្រូវបានអនុម័ត, មូលនិធិទូទៅរបស់ទីក្រុង (City's General Fund) នឹងទទួលបាន ១,៦ លានដុល្លារ បន្ថែមទៀត។ ជាផ្នែកមួយនៃដំណើរការរៀបចំថវិការ, អ្នកគ្រប់គ្រងទីក្រុង នឹងធ្វើសំណើទៅក្រុមប្រឹក្សាក្រុង ដើម្បីធ្វើការចំណាយនូវចំណូលថ្មីនោះ, ស្របតាមដំណោះស្រាយអាទិភាពនៃការចំណាយ ដែលបានអនុម័តដោយក្រុមប្រឹក្សាក្រុង។ សំណើនោះ នឹងត្រូវដាក់ជូនអភិបាលក្រុង និងក្រុមប្រឹក្សាក្រុង នៅខែសីហា ឆ្នាំ ២០២១, ជាមួយនឹងការសម្រេចចិត្តថវិការចុងក្រោយ ដែលត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាក្រុង ត្រឹមថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២១, ដើម្បីចាប់ផ្តើមការចំណាយនៅថ្ងៃទី ១ ខែតុលា ឆ្នាំ ២០២១។

## តើមានអ្វីកើតឡើង ប្រសិនបើ Measure US មិនត្រូវបានអនុម័ត?

- ប្រសិនបើ Measure US មិនត្រូវបានអនុម័ត, មូលនិធិទូទៅរបស់ទីក្រុង នឹងមិនទទួលបានប្រាក់ចំនួន ១,៦ លានដុល្លារបន្ថែមទៀតឡើយ ដើម្បីចំណាយលើវិស័យអាទិភាពផ្សេងៗនានា ដែលបានកំណត់ដោយក្រុមប្រឹក្សាក្រុង។

## តើនឹងមានអ្វីកើតឡើងបន្ទាប់ ជាមួយនឹងពន្ធដែលបានស្នើសុំ?

- អ្នកបោះឆ្នោតនឹងសម្រេចចិត្តនៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០ ថាតើត្រូវអនុម័ត ឬបដិសេធការដំឡើងពន្ធបារ៉ែល។ រាល់ថវិការថ្មី ដែលបង្កើតដោយការដំឡើងអត្រា នឹងត្រូវបានពិនិត្យឡើងវិញដោយអភិបាលក្រុង និងក្រុមប្រឹក្សាក្រុងជារៀងរាល់ឆ្នាំ ហើយត្រូវបានប្រើប្រាស់តាមរយៈដំណើរការថវិការប្រចាំឆ្នាំ ដោយមានការចូលរួមពីសហគមន៍។

## ខ្ញុំមានសំណួរនានា អំពីព័ត៌មានដែលខ្ញុំបានទទួលពីយុទ្ធនាការមួយ។ តើខ្ញុំនិយាយរឿងនេះ ជាមួយអ្នកណា?

- បុគ្គលិកទីក្រុង មិនអាចឆ្លើយសំណួរនានាអំពីយុទ្ធនាការណាមួយបានឡើយ។ សាលាក្រុងអាចផ្តល់តែព័ត៌មានអព្យាក្រឹត និងអង្គហេតុនានាស្តីអំពីវិធានការណ៍, ដូចជាសន្លឹកអង្គហេតុនេះ។ សំរាប់សំណួរនានាទាក់ទងទៅនឹងយុទ្ធនាការណ៍ជាក់លាក់ណាមួយ, សូមទាក់ទងយុទ្ធនាការណ៍នីមួយៗ ដើម្បីគាំទ្រ ឬប្រឆាំងនឹងវិធានការណ៍នេះ។

# វិធានការណ៍សន្លឹកឆ្នោត ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០២០

# ពន្ធផលិតកម្មប្រេងបារ៉ែលទីក្រុងឡុងប៊ីច (ពន្ធបារ៉ែល/ធុង)

# សំណួរនានា ដែលបានសួរជាញឹកញាប់

**តើខ្ញុំអាចមើលវិធានការណ៍សន្លឹកឆ្នោត និងបទបញ្ញត្តិផ្សេងៗអមជាមួយ សម្រាប់ Measure US នៅឯណា?**

- ព័ត៌មានទាំងអស់ ស្តីពីពាក្យជាក់លាក់នៃ Measure US, ការវិភាគច្បាប់មិនលំអៀង និងឯកសារនានាផ្សេងទៀត អាចរកបាន នៅឯ www.longbeach.gov/cityclerk.

*ព័ត៌មានលើសន្លឹកអង្គហេតុនេះ គឺសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ដើម្បីពិពណ៌នាអំពីផលប៉ះពាល់ជាក់ស្តែងនៃវិធានការណ៍អាមេរិក (Measure US)។ សន្លឹកអង្គហេតុព័ត៌មាននេះ មិនធ្វើការតស៊ូមតិអោយបោះឆ្នោតថាបាទ/ចាស ឬទេ ចំពោះវិធានការណ៍នេះ នោះឡើយ។*